**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៦ សរណន

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ ២០០៧

# សារាចរណែនាំ

## ស្តីពី

## ការអនុវត្តផែនការបែងចែកសម្បទានដីសង្គមកិច្ច

រាជរដ្ឋាភិបាលបានពិនិត្យឃើញថា ចាប់ពីប្រទេសជាតិបានទទួលសន្តិភាពពេញលេញដោយសារនយោបាយ ឈ្នះ ឈ្នះ បានធ្វើឱ្យសភាពការណ៍កម្ពុជាមានការរីកចំរើនយ៉ាងឆាប់រហ័ស ។ សភាពការណ៍សេដ្ឋកិច្ច សង្គម ក្នុងនេះទីផ្សារដី មានការវិវត្តន៍ប្រែប្រួលយ៉ាងលឿន ធ្វើឱ្យដីធ្លីមិនគ្រាន់តែជាមធ្យោបាយផលិតកម្មប៉ុណ្ណោះទេ ‘ តែជាប្រភពធនធានហិរញ្ញវត្ថុយ៉ាងសំខាន់របស់ប្រជាពលរដ្ឋ ក្នុងការកែលំអជីវភាពរស់នៅ ក៏ដូចជាការវិនិយោគលើគ្រប់ផ្នែក ។ ទន្ទឹមនេះ អត្រាកំណើនខ្ពស់នៃប្រជាពលរដ្ឋ និងការវិវត្តន៍ដ៏លឿននៃទីផ្សារដី បានធ្វើឱ្យមានតម្រូវការដីធ្លី សំរាប់សាងសង់លំនៅដ្ឋាននិងប្រកបរបរកសិកម្ម ពិសេសចំពោះគ្រួសារក្រីក្រ និងយោធិនរំសាយ ក៏បានកើនឡើងដែរ ។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ ស្តីពីសម្បទានដីសង្គមកិច្ច សំរាប់គាំទ្រដល់ការអនុវត្តគោលនយោបាយបែងចែកដីធ្លីប្រកបដោយសមធម៌ ដូចដែលមានចែងក្នុងឯកសារបឋមស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី ។ អនុវត្តនូវស្មារតីនៃអនុក្រឹត្យនេះ រាជរដ្ឋាភិបាលបានធ្វើការបែងចែកដី និងធ្វើនិយតកម្មការកាន់កាប់ដីធ្លីដោយប្រជាពលរដ្ឋក្រីក្រ សំរាប់ប្រជាពលរដ្ឋរាប់ម៉ឺនគ្រួសារជាបន្តបន្ទាប់ ។

ដើម្បីជំរុញការអនុវត្តឱ្យបានជោគជ័យ នូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ ដែលបានកំណត់ឱ្យជំរុញការបែងចែកដីសម្បទានសង្គមកិច្ច ដល់គ្រួសារក្រីក្រដែលខ្វះដី និងឬគ្មានដី ឱ្យបានយ៉ាងតិច ១០.០០០ គ្រួសារ ដល់ឆ្នាំ ២០០៨ រាជរដ្ឋាភិបាលសូមធ្វើការណែនាំ ដូចខាងក្រោម ៖.

១. អភិបាលគ្រប់ខេត្តក្រុង ដែលជាប្រធានគណៈកម្មាធិការប្រើប្រាស់និងបែងចែកដីខេត្តក្រុង ត្រូវរៀបចំផែនការបែងចែកដីសម្បទានសង្គមកិច្ច ទាំងការជ្រើសរើសដី ការធ្វើផែនការប្រើប្រាស់ដី និងការជ្រើសរើសមុខសញ្ញាអ្នកទទួលដី ចាប់ពីពេលនេះរហូតដល់ពាក់កណ្តាល ឆ្នាំ ២០០៨ ក្នុង ០១ខេត្តក្រុង ឱ្យបានយ៉ាងតិចជាមធ្យមសំរាប់ ៤១៦គ្រួសារ ។ ចំពោះខេត្តក្រុងណាដែលមានលទ្ធភាពដីច្រើន ត្រូវធ្វើការជ្រើសរើសដីឱ្យបានលើសមធ្យមភាគខាងលើ ដើម្បីរួមចំណែក ជួយដោះស្រាយដល់ខេត្តក្រុងដែលខ្វះដី ។ ទន្ទឹមនឹងនេះ ត្រូវកសាងផែនការអភិវឌ្ឍន៍ទីតាំងបែងចែកដីសម្បទានសង្គមកិច្ច ដើម្បីរៀបចំផែនការថវិកាចំណាយបញ្ចូលក្នុងគំរោងថវិកាជាតិឆ្នាំ ២០០៩ ។ ផែនការអភិវឌ្ឍន៍នេះ ត្រូវយកចិត្តទុកដាក់ជាសំខាន់ ធ្វើឱ្យមានការប្រែប្រួលខាងជីវភាព និងសុខមាលភាពរបស់អ្នកទទួលដីសម្បទានសង្គមកិច្ច មានជាអាទិ៍ ប្រភពផ្គត់ផ្គង់ទឹក ផ្លូវថ្នល់ មណ្ឌលសុខភាព សាលារៀន ។ល។

២. គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ សហការជាមួយគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីណែនាំតម្រង់ទិសឱ្យគ្រប់ខេត្តក្រុង ស្រុកខណ្ឌ ឃុំសង្កាត់ អនុវត្តឱ្យបានត្រឹមត្រូវតាមស្មារតីនៃអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីសម្បទានដីសង្គមកិច្ច។

៣. គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវរាយការណ៍តាមជំហានការងារ ជូនរាជរដ្ឋាភិបាល ស្តីពីលទ្ធផលនៃការអនុវត្តសារាចរនេះ ។

ទទួលបានសារាចរណែនាំនេះ រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន អភិបាលគ្រប់ខេត្តក្រុង ស្រុកខណ្ឌ ក្រុមប្រឹក្សាគ្រប់ឃុំសង្កាត់ ត្រូវចាត់តាំងអនុវត្តតាមការណែនាំខាងលើ ដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាព ។

ហ៊ុន សែន